# របាយការណ៍ស្តីពី
# ដំណោះស្រាយវិវាទសម្រាប់ពលករទេសន្តរប្រវេសន៍
# ដែលទៅធ្វើការនៅបរទេសតាមរយៈក្រុមហ៊ុនស្របច្បាប់

ថ្លែងដោយឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្នុងឱកាសសិក្ខាសាលាជាតិស្តីពីការពង្រឹងការអនុវត្តច្បាប់

ដើម្បីយុត្តិធម៌ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦

-សូមគោរព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាទីគោរព!

-សូមគោរពឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និង ភ្ញៀវអន្តរជាតិ ជាទីរាប់អាន!

ក្នុងនាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមក្រុមការងារទេសន្តរប្រវេសន៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំមានកិត្តិយសដែលសិក្ខាសាលាថ្នាក់ជាតិពេលនេះបានផ្តល់ឱកាសឱ្យខ្ញុំ បានធ្វើរបាយការណ៍អំពីដំណោះស្រាយវិវាទសម្រាប់ពលករទេសន្តរប្រវេសន៍ ក្នុងចំណោមពលករដែលបានចេញទៅធ្វើការនៅបរទេសតាមរយៈក្រុមហ៊ុនដែលជាទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំ និងអនុវត្តតាម

គោលនយោបាយ បទបញ្ញា និងនីតិវិធី ស្របតាមច្បាប់ និងបទបញ្ញត្តិជាតិ ដោយមានយន្តការដ៏សមស្របសម្រាប់អនុវត្ត ធានាបាននូវការការពារ និងការលើកកម្ពស់សិទ្ធិពលករ។

គោលនយោបាយស្តីពីទេសន្តរប្រវេសន៍កម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០ និងត្រូវបានពិនិត្យកែសម្រួលឡើងវិញក្នុងឆ្នាំ២០១៤។ គោលនយោបាយនេះត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃគោលនយោបាយជាតិស្តីពីមុខរបរនិងការងារកម្ពុជាឆ្នាំ២០១៥-២០២៥។

ផ្អែកលើគោលនយោបាយស្តីពីទេសន្តរប្រវេសន៍កម្ពុជា អនុក្រឹត្យលេខ៥៧ ឆ្នាំ១៩៩៥ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ត្រូវបានពិនិត្យឡើងវិញជាថ្មី និងបានប្តូរមកជាអនុក្រឹត្យលេខ១៩០ ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមទីភ្នាក់ងារជ្រើសរើសឯកជន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសចំនួន៨ ដើម្បីគ្រប់គ្រង និងលើកកម្ពស់សិទ្ធិ ផលប្រយោជន៍ ការការពារពីការរំលោភបំពាន ការកេងប្រវ័ញ្ច និងការជួញដូរមនុស្ស ដោយសហការជាប្រចាំជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ។

បន្ថែមលើបទប្បញ្ញត្តិជាតិ ក្រសួងបានសហការជាមួយស្ថាប័នមានសមត្ថកិច្ចប្រទេសទទួលពលករខ្មែរ និងបានបង្កើតកិច្ចព្រមព្រៀងទ្វេភាគី សម្រាប់ការគ្រប់គ្រង និងការពារពលករខ្មែរ ដែលត្រូវបានបញ្ជូនទៅធ្វើការនៅប្រទេសនីមួយៗ ដោយភ្ជាប់ជាមួយឯកសារពាក់ព័ន្ធផ្សេងៗ ជាពិសេសនីតិវិធីសម្រាប់ការអនុវត្ត។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្រុមមន្ត្រីអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ទទួលបន្ទុកតាមឃ្លាំមើល និងធ្វើការណែនាំតម្រង់ទិសការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជនជាប់ជាប្រចាំ ដើម្បីពង្រឹងប្រសិទ្ធិភាពនៃការការពារពលករ និងជៀសវាងរាល់សកម្មភាពដែលនាំទៅដល់ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការជួញដូរមនុស្ស។

តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងដំណើរការមួយនេះ នៅតែកើតមានឡើងផងដែរនូវអំពើអសកម្មមួយចំនួនរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ដែលបានធ្វើឱ្យកើតមានឡើងនូវការកេងប្រវ័ញ្ច និងការជួញដូរកម្លាំងពលកម្ម ក៏ដូចជា ការជួញដូរមនុស្ស ទោះបីវាជាករណីដ៏តិចតួចក៏ដោយ តែវាក៏មានកើតចេញជាវិវាទនៃពលករទេសន្តរប្រវេសន៍ ដែលទាមទារនូវការដោះស្រាយមួយឱ្យបានសមស្រប ជូនភាគីដែលជាប់ពាក់ព័ន្ធ។

ឆ្លើយតបទៅនឹងតម្រូវការដ៏ចាំបាច់មួយនេះ ប្រព័ន្ធដោះស្រាយវិវាទសម្រាប់ពលករទេសន្តរប្រវេសន៍នៅកម្ពុជា ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការ តាមរយៈប្រកាសលេខ២៤៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានទីតាំងនៅនាយកដ្ឋានមុខរបរ និងហាត្ថពលកម្ម និងនៅក្នុងមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ (MRC) នៅខេត្តបាត់ដំបង ខេត្តកំពង់ចាម និងខេត្តព្រៃវែង និងកំពុងបន្តរៀបចំយន្តការនេះឱ្យបានគ្រប់ខេត្ត ព្រមទាំងកំពុងរៀបចំកសាងធនធានមនុស្ស សម្រាប់ទទួលធ្វើការងារនេះ ក្នុងគោលដៅពង្រឹងប្រសិទ្ធិភាពនៃសេវា និងបង្ខិតសេវានៃការដោះស្រាយវិវាទពលករទេសន្តរប្រវេសន៍ ឱ្យបានចូលទៅកាន់តែជិតប្រជាពលរដ្ឋ។

*-សម្តេចក្រឡាហោម ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !*

បច្ចុប្បន្ន មានទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ចំនួន ៧១ ក្រុមហ៊ុន ដែលក្នុងនោះក្រុមហ៊ុនកំពុងដំណើរការមានចំនួន ៥៩ក្រុមហ៊ុន និងមិនមានដំណើរការចំនួន១២ក្រុមហ៊ុន។ ក្នុងឆ្នាំ២០១៦នេះ ក្រសួងបានធ្វើអធិការកិច្ច និងបានចាត់វិធានការដោះស្រាយបញ្ហាដែលកើតឡើងចំពោះពលករ ដូចខាងក្រោម៖

១ បានដាក់កំហិតឱ្យក្រុមហ៊ុនរៀបចំបែបបទ និងលក្ខខណ្ឌសម្រាប់ក្រុមហ៊ុន និងមជ្ឈមណ្ឌលណែនាំតម្រង់ទិសឱ្យបានត្រឹមត្រូវតាមការកំណត់ ចំនួន៣៩ក្រុមហ៊ុន ដោយបានដាក់កំហិតចំនួន ៣៩ លើក។

២ បានផ្អាកដំណើរការក្រុមហ៊ុន រយៈពេលពី ២សប្តាហ៍ទៅ១ខែ សម្រាប់ទុកពេលឱ្យដោះស្រាយបញ្ហាដែលកើតឡើង ចំនួន០២ក្រុមហ៊ុន។ ក្រុមហ៊ុន០១ត្រូវបានបើកឱ្យដំណើរការវិញ និងក្រុមហ៊ុន១ទៀត ដោយមិនអាចអនុវត្តបានត្រឹមត្រូវតាមការកំណត់ ត្រូវបានបញ្ឈប់ជាស្ថាពរ ។

៣ ក្នុងឆ្នាំ២០១៦ ពលករចំនួន១៨៧នាក់ (ស្រី ៥៨នាក់) បានដាក់ពាក្យប្តឹងក្រុមហ៊ុនចំនួន២៨ លើសំណុំរឿងចំនួន៥៤ ទាមទារឱ្យសងការខូចខាត ដោយសារក្រុមហ៊ុនមិនអនុវត្តតាមកិច្ចសន្យាសេវារកការងារឱ្យធ្វើ ។ ក្រសួងបានពិនិត្យ និងដោះស្រាយវិវាទទាំងនោះបានសះជាចំនួន ១៩សំណុំរឿង និងបានទុកថាជាមោឃៈចំនួន ១៣ សំណុំរឿង។ មរណៈភាពពលករ០១នាក់ ត្រូវបានដោះស្រាយតាមច្បាប់ប្រទេសទទួល។ កំពុងបន្តតាមដាន ករណីពលកររត់បាត់ខ្លួនចំនួន ០១នាក់នៅប្រទេសជប៉ុន និង ០១នាក់ទៀតនៅប្រទេសម៉ាឡេស៊ី។

ករណីដែលកើតឡើង និងបានដោះស្រាយក្នុងឆ្នាំ២០១៦ ធូរស្រាលជាងឆ្នាំ២០១៥។ ក្នុងឆ្នាំ២០១៥ ពលករ២៨៥នាក់ បានប្ដឹងក្រុមហ៊ុនចំនួន០២។ ក្រុមហ៊ុនទាំងពីរព្រមសងប្រាក់ដល់ពលករចំនួន ១៤៤ ៨៥៣ដុល្លារអាមេរិក តែដោយក្រុមហ៊ុនមានប្រាក់សងបានតែចំនួន ៤៦ ៥៥៣ដុល្លារអាមេរិក ទើបក្រសួងបានដាក់បញ្ជាឱ្យក្រុមហ៊ុនដកប្រាក់កក់នៅធនាគារចំនួន ៩៨ ៣០០ ដុល្លារអាមេរិក ដើម្បីទូទាត់សងជូនពលករបានគ្រប់ចំនួន។

*-សម្ដេចក្រឡាហោម ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !*

ឆ្លងតាមដំណើរការគ្រប់គ្រងលើការបញ្ជូនពលករទៅធ្វើការនៅបរទេសអស់រយៈពេលជាងមួយទសវត្ស ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានអនុវត្តតាមគោលការណ៍ជាតិនៃការជ្រើសរើសដោយត្រឹមត្រូវ (National Fair Recruitment Principles) ស្របតាមបទប្បញ្ញត្តិជាតិ និងគោលការណ៍ណែនាំរបស់អង្គការពលកម្មអន្តរជាតិ សំដៅធានាសិទ្ធិ និងសុវត្ថិភាពពលករទេសន្តរប្រវេសន៍ ក៏ដូចជាការទប់ស្កាត់ និងការពារពលករឱ្យជៀសផុតពីការកេងប្រវ័ញ្ច និងការជួញដូរ នៅគ្រប់ដំណាក់កាលនៃវដ្តទេសន្តរប្រវេសន៍ការងារ ដូចខាងក្រោម៖

១ ការជ្រើសរើសត្រូវអនុវត្តដោយគោរព និងការពារសិទ្ធិរបស់ពលករ ក្នុងការទទួលយកការងារណាមួយ និងស្របតាមបទប្បញ្ញត្តិជាតិជាធរមាន និងអនុលោមតាមបទប្បញ្ញត្តិអន្តរជាតិ ដោយត្រូវជៀសវាងការងារដោយបង្ខំ និងពលកម្មកុមារ ឬការរើសអើងនានា។

២ ការជ្រើសរើសត្រូវតែឆ្លើយតបតាមសេចក្ដីត្រូវការនៃទីផ្សារការងារពិត ដែលធានាបាននូវការងារសមរម្យ ដែលមានលក្ខខណ្ឌការងារល្អ និងទទួលបានប្រាក់ឈ្នួលដ៏ត្រឹមត្រូវ។ ទាំងអស់នេះធានាថា ទៅដល់ប្រទេសទទួលពលករ ពលករពិតជាមានការងារធ្វើ ហើយពលករពិតជាអាចទទួលយកការងារនោះធ្វើដោយស្ម័គ្រចិត្ត។

៣ បទប្បញ្ញត្តិជាតិទាក់ទងដល់ការជ្រើសរើសពលករ ត្រូវបានដាក់ឱ្យទីភ្នាក់ងារជ្រើសរើសឯកជន ក៏ដូចជាភ្នាក់ងារនានានៃទីភ្នាក់ងារឯកជនអនុវត្តដ៏ត្រឹមត្រូវ ដោយមានការតាមឃ្លាំមើលរបស់អធិការការងារទទួលបន្ទុកខាងមុខរបរនិងហត្ថពលកម្ម ជាប់ជាប្រចាំ។

៤ ក្នុងការជ្រើសរើស ត្រូវតែលើកកម្ពស់ឱ្យមានការអនុវត្តប្រកបដោយតម្លាភាព ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករ ដោយពលករត្រូវតែទទួលបាននូវការណែនាំតម្រង់ទិសពលករ ការរៀនភាសា និងការហាត់ជំនាញការងារ ឱ្យបានគ្រប់គ្រាន់។

៥ ការអនុវត្តបទបញ្ញា និងសកម្មភាពនៃការជ្រើសរើសពលករ ត្រូវបានយកចិត្តទុកដាក់ជាពិសេស ពីអធិការការងារទទួលបន្ទុក ដើម្បីជៀសឱ្យបានផុតពីការបោកប្រាស់ ការរំលោភបំពាន និងការជួញដូរ ក្នុងគោលដៅធានាបាននូវភាពស្របច្បាប់នៃពលករទៅតាមបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសទទួលពលករ។

៦ ការជ្រើសរើស ត្រូវតែអនុវត្តតាមការព្រមព្រៀងគ្នារវាងកម្ពុជា និងប្រទេសទទួល ឬ MOU ក៏ដូចជា នីតិវិធីប្រតិបត្តិជាពិសេស សម្រាប់អនុវត្តកិច្ចព្រមព្រៀងទ្វេភាគី។ កិច្ចសន្យាការងាររវាងពលករ និងនិយោជកដែលពលករត្រូវធ្វើការជូន ត្រូវតែបានចុះហត្ថលេខាដោយពលករ និងនិយោជក នៅមុន និងពេលពលករចេញដំណើរទៅប្រទេសទទួល។ កិច្ចសន្យាការងារនេះ ត្រូវតែទទួលបានការពិនិត្យ និងចុះទិដ្ឋាការរបស់អធិការទទួលបន្ទុក។

៧ តម្លៃនានា ដែលត្រូវបង់សម្រាប់ទីភ្នាក់ងារ ឬសម្រាប់ការងារចាំបាច់នានា ត្រូវតែមានការពិនិត្យ និងយល់ព្រមរបស់អាជ្ញាធរមានសមត្ថកិច្ចនៃកម្ពុជា និងប្រទេសទទួលពលករ។

៨ កិច្ចសន្យាការងារដែលប្រទេសទទួល និងកម្ពុជា បានរៀបចំជាបទដ្ឋានអប្បបរមា គឺត្រូវបានរៀបចំភ្ជាប់ជាមួយMOU។ កិច្ចសន្យានេះត្រូវបានដាក់ឱ្យអនុវត្តជាកាតព្វកិច្ច លើកលែងតែ មានកិច្ចសន្យាដែលផ្តល់សិទ្ធិ និងផលប្រយោជន៍ដល់ពលករល្អប្រសើរជាង។

៩ ប្រទេសទទួលពលករ ត្រូវធានាថា ក្នុងប្រទេសខ្លួន ពលករមានសិទ្ធិគ្រប់គ្រាន់ក្នុងការធ្វើដំណើរ ដូចប្រជាជនខ្លួន លើកលែងតែមានបទប្បញ្ញត្តិជាក់លាក់ជាពិសេស។

១០ ពលករមានសិទ្ធិទទួលបាន របបសន្តិសុខសង្គមនានា ស្របតាមច្បាប់ និងបទបញ្ញានៃប្រទេសទទួល ដូចជាពលករដែលជាជនជាតិនៃប្រទេសទទួលនេះ។

១១ ពលករត្រូវតែទទួលបានការរៀបចំ និងការធ្វើមាតុភូមិនិវត្តវិញ ស្របតាមការកំណត់នៃកិច្ចសន្យការងារ និងតាមការស្ម័គ្រចិត្ត និងស្របតាមករណីជាពិសេសនីមួយៗនៃពលករ។

១២ ពលករមានសិទ្ធិទទួលបានដំណោះស្រាយវិវាទការងារស្របតាមប្រព័ន្ធនៃការដោះស្រាយវិវាទការងារនៃប្រទេសទទួល ដូចជាពលករជាជនជាតិនៃប្រទេសនេះ។ នៅពេលដែលមកដល់កម្ពុជាវិញ ពលករក៏ទទួលបានដំណោះស្រាយវិវាទការងារ តាមប្រព័ន្ធនៃការដោះស្រាយវិវាទការងារពលករនៃកម្ពុជាផងដែរ ទោះបីជាវិវាទនោះកើតនៅទីណាក៏ដោយ។

**សូមអរគុណ!**